# ២-រឿងមាយើង

## បទកាកគតិ

អញខ្ញុំក្រួញក្រប សិរសាស្រប៉ាប លុតលើកហត្ថា ទសង្គុលី អភិវន្ទា នៃព្រះពុទ្ធជា ឥស្សរភពត្រី ។ ព្រះអង្គឧត្តម លើសលើឥន្ទព្រហ្ម មូលមកភក្តី ប្រកបប្រការ សម្ភាររឹទ្ធី បរិបូណ៌បារមី ពិសេសថ្កើងថ្កាន ។ បង្គំព្រះធម៌ ពិសេសមាន អាថ៌ ជ្រៅពន់ប្រមាណ ស្មោះស្មើភេត្រា ថ្លៃថ្លាមែនមាន បវរទិព្វញ្ញាណ ផ្ទឹមផ្ទុកសព្វសត្វ ។ បង្គំព្រះប្រសើរ ឧត្តុង្គឧត្តម ពេកក្លាន់ អាចនាំសត្វឆ្លង រំលងវាលវដ្ត ដល់ឋានអម័ត2 បូរីនាយណាយ ។ ទើបខ្ញុំបង្គំទិព្វទេព ឧត្តម សោឡសសួគ៌ា សូមសុខសួស្តី សិរីទីឃា យុឃឹតសុខសា- ប្បាយបរិបូណ៌បុណ្យ ។

ស្រេចខ្ញុំនឹងថ្លែង ដំណើរដំណែង ដំណាលពីមុន មានក្សត្រមួយថ្លៃ ប្រពៃលើសលន់ គ្រប់គ្រង មហាជន ក្រុងពារណសី ។ ព្រះនាមព្រះបាទ ព្រហ្មទត្តនរនាថ លើសលើលោកិយ ប្រកបជាយា អាឃិអគ្គមហេសី កបកល្យាណី រូបរត្នសោភា ។ ព្រះស្នំសាវជៃ ពិសេសច្រើនក្រៃ សម្រាប់ក្សត្រគាល់សព្វថ្ងៃ ក្រាស់ក្រៃគណនា ប្រដូចតារា កររៀបរៀងរាយ ។ មន្ត្រីយោធា ស្រមណ៍ព្រាហ្មណ៍គណា -ចារ្យចេះប្រាជ្ញប្រាយ សម្រាប់មហាក្សត្រ ព្រហ្មទត្តរឹទ្ធីសាយ ពលពាលទាំងឡាយ អនេកសំខេយ្យា3 ។ ស្ដេចសោយរាជ្យស្កល់ ឥតកោលាហល រដ្ឋរាស្ត្រប្រជា ទ្រង់ទសពិធរាជ អង់អាចអាសា អាសូរករុណា ចិញ្ចឹមរៀបរង ។ ក្សត្រក្សាន្តសោយរាជ្យ ថ្កើងព្រះអំណាច ឥតបីផ្ទឹមផង ស្ដេចផ្ចាញ់សត្រូវ អាស្រូវយង់ឃ្នង ពុំអាចប្រឡង សុខសល់លើសលន់ ។ កាលនោះមានមា- ណពនៅភារា ក្សត្រថ្លៃមានបុណ្យ ជាអ្នកទុគ៌ត ក្សិណខ្សត់ទ្រព្យធន តែប្ដីប្រពន្ធ និត្យនៅសព្វថ្ងៃ ភរិយានោះណា មានរូបសោភា សក្តិសមល្មមល្មៃ តែចិត្តនោះមិញ កំណាញ់ពេកក្រៃ ព្រៀងលានទីឯទៃ គេពុំចូលចិត្ត ។ មានកាលមួយថ្ងៃ ចៅមាណពនៃ ទៅរកជញ្ជាត់ នឹងភរិយាប្រាណ ដោយដានកម្សត់ ពិបាកពេកក្ដាត់ ទុគ៌តក្រក្រៃ ។ កញ្ជើសោតធ្លុះ ដាចដាច់រលុះ ដោយមុំនោះនៃ រីឯភរិយា ឥតអធ្យាស្រ័យ ពុំគន់រំពៃ ថៃទាំឡើយហោង ។ ប្ដីតែងជញ្ជាត់ ដាក់ទៅជ្រុះបាត់ តាមមុំនោះផង ឥតសព្វឥតសារ ឥតការជាម្ដង ហេតុឥតចិត្តចង រំពងនាំពា ។ ជញ្ជាត់រៀងទៅ ដួចដល់សំពៅ ធារធំមហិមា រីនាយសំពៅ និត្យនៅភរិយា មើលពីភេត្រា យល់កញ្ជើធ្លុះ ។ នាងនាយភេត្រា ស្រដីទៅថា នាងជញ្ជាត់នោះ ម្ដេចមុំគិតធ្វើ កញ្ជើនាងធ្លុះ យកអីចុកចុះ សោះវាលិចបាន ។ ក្សិណនាយសំពៅ ក្រោធក្រៃថាទៅ នឹងភរិយាប្រាណ បើចេះដូច្នោះ មឹងចុះទៅថ្កាន កាន់កញ្ជើបាន ជាប្រពន្ធវា ។ អញនឹងប្ដូរយក ប្រពន្ធវាមក នៅលើភេត្រា ជាប្រពន្ធអញ រីឯវិញហោងណា ត្បិតចៅជាងវា បង្គាប់ធ្មួនថៃ ។ នាងស្ដាប់ប្ដីថា នឹងដូរភរិយា ឯងឱ្យទៅគេ ដោយពាក្យពុំស្រួល ពុំគួរបើជេរ ខ្លួនគ្មានទោសទេ ម្ដេចចងទោសា ។ ទើបនាងឆ្លើយទៅ កាន់នាយសំពៅ ជាប្ដីអាត្មា ពាក្យខ្ញុំទ្រគោះ លើសលស់ត្រង់ណា ក៏ដល់អ្នកជា ប្ដីពុំចូលចិត្ត ។ និងយកខ្ញុំទៅ ដូរមាណពនៅ កាន់ឈ្មោងជញ្ជាត់ បើអ្នកដូរនៅ ខ្ញុំទៅនឹងគាត់ ខ្ញុំសោតគ្មានមាត់ ប្រកែកថាអ្វី ។ ទើបនាយសំពៅ ស្រេចស្រែកហៅទៅ បុរសនោះខ្មី ថាចៅហ៊ានដូរ ប្រពន្ធឬអ្វី មកអាយស្រដី ឱ្យជាក់នឹងគ្នា ។ មាណពជញ្ជាត់ ព្ធនាយនោះគាត់ ស្ដីដូរភរិយា ខ្លាចខ្លួនពុំហ៊ាន ទៅថ្កានភេត្រា នាយនោះរែងជា ហៅខ្វាន់ៗទៅ ។ ទើបមាណពនោះ ទន្ទបចូលស្មោះ ឡើងលើសំពៅ ទាំងប្ដីប្រពន្ធ អង្គុយនិត្យនៅ ទៀបនាយសំពៅស្រដីទៀងថា ។ ចៅអើយកុំយូរ មកយើងនឹងប្ដូរ ប្រពន្ធផងគ្នា អញទៅចៅណា ចៅឱ្យភរិយា ចៅមកអញហោង ។ មាណពកម្សត់

ស្តាប់យល់ទាស់បទ ពុំហ៊ានសាសង នាយនោះរ៉ែងរួន ផ្គួនៗច្រើនដង ថាហើយថាផង ជាច្រើនភាសា ។ ទើប មាណពនោះ ថាតាមចំពោះ ចិត្តអ្នកហោងណ៎ា ខ្ញុំជាអ្នកហោច ត្រមោចកំព្រា ឥតបើនឹងថា ទាស់ទែងសេចក្តី ។ នាយសំពៅស្តាប់ អស់អាថ៌សារសព្វ ត្រេកអរបេតី ក្សេមក្សាន្តកន្លង ដណ្តើមឃ្មាតខ្មី ថាហៃប្អូនស្រី ឯណោះសោត ហោង ។ ថានាងប្អូនស្និទ្ធ ស្នេហ៍ស្នាលចូលចិត្ត ព្រមមូលនឹងបង ឬមួយពុំមូល ពុំចូលចិត្តបង ចូរចៅសាសង ឥឡូវ នេះណ៎ា ។ ឯមេបញ្ជី ផ្គុះអរលលើ ចង់នាយនាវា សើចហើយញញឹម មើលចុងនេត្រា ឱនហើយទើបថា គូពីព្រេង ហោង ។ ឯនាងភរិយា ចៅនាយភេត្រា ស្តែងស្តាប់សាសង ប្តីប្តូរផ្តែផ្តាច់ ពាក្យពេចន៍ជាម្តង នាងចរចុះផង ពីលើ ភេត្រា ។ តែស្បៃនៅក នាងដើរចុះមក កាន់ប្តីកំព្រា ទ្រព្យធនពុំយក ដិតមកអាត្មា នាងឈោងប្រវា កញ្ជើកាន់ទៅ ។ បោចបានសំរាម មកចុកជិតភ្លាម ពិតពុំឱ្យសៅ នាងកាន់តាមប្តី ជញ្ជូកតាមស្មៅ បានស្រេចទើបទៅ ឋានប្តីនោះណា ។ លុះដល់លំនៅ នាងដណ្តឹងទៅ កាន់ប្តីនាងថា អ្នកអើយអស់ផ្ទះ រៀងខាងនេះណ៎ា ជាញាតិការ សន្តានផៅពណ៌ ។ ឬជាព្រៀងលាន ត្បិតខ្ញុំពុំមាន ដឹងញាតិនិមល បើអ្នកឯណា ជាញាតិបវរ ព្រៀងលានស្មោះស អ្នកប្រាប់ខ្ញុំរ៉ា ។ ប្តី ឆ្លើយរឹងទៅ នាងអើយញាតិផៅ បងគ្មានទេណ៎ា សឹងតែព្រៀងលាន នៅឋានទៀបគ្នា សព្វថ្ងៃកំព្រា គ្មានបងប្អូន ឡើយ ។ នាងឮប្តីថា ឥតញាតិវង្សា កំព្រាហើយ ហេតុនាងសប្បុរស យកគេជាត្រើយ នាងពុំគិតឡើយ កម្សត់អាត្មា ។ នាងយកត្រីនោះ ឱ្យប្តីនាងស្មោះ ជូនចែកគ្រប់គ្នា តិចៗគ្រប់មុខ អ្នកស្រុកនៅនា ព្រៀងលានស្គាល់គ្នា ខេត្តខាងលំ នៅ ។ ប្តីសោតទៅស្មោះ ដោយប្រពន្ធនោះ បង្គាប់ប្រដៅ កាលនោះព្រៀងលាន ខាងឋានលំនៅ សឹងគិតថាចៅ នេះ ដែលឯណា ។ សប្បុរសដូច្នេះ ផ្ញើលអ្វីម្តងនេះ ជូនយើងគ្រប់គ្នា សព្វដងកំណាញ់ កន្ទ្រឹសប្ញស្សា ឥឡូវម្តេចជា សប្បុរសពេកក្រៃ ។ អ្នកផងគិតហើយ ពិតពុំលងឡើយ មានកាលមួយថ្ងៃ គេដើរទៅលេង និងមាណពនៃ យល់នាង ប្រពៃ មានរូបសោភា ។ ទើបគេគិតឆ្ងៃ ថាចៅនេះនៃ គាត់បានភរិយា ទៀតទើបសប្បុរស ពុំដូចសព្វគ្រា នាងនេះ លក្ខណា មារយាទហ្មត់ហ្មង ។ មានកាលមួយថ្ងៃ មាណពទៅព្រៃ រកកាប់ឧសចង បាច់បានរែកមក ដូចកាលសព្វ ដង រឺឈើនោះផង ពុំឈើខ្ចីខ្ជា ។ សឹងឈើប្រពៃ មែនមានតម្លៃ ក្លាំពាក់ក្រិស្នា នាងយល់ឧសប្តី បានពីព្រឹក្សា សឹង ឈើជាៗ មានៗតម្លៃ ។ នាងគិតឯងថា ប្តីអញនេះណា បានឈើប្រពៃ ពុំស្គាល់ជាឈើ នោះមានតម្លៃ យកមកសព្វ ថ្ងៃ ដុតដូច្នេះណា ។ សមហើយនេះមាន ក្រាស់ក្រៃនាឋាន អាយឯងទើបជា ឱអស់អ្នកផង ពុំស្គាល់ក្រស្នា ក្លាំពាក់ យកជា ឧសឥតគិតឡើយ ។ ទើបនាងនារី ដណ្តឹងទៅប្តី ថាហៃអ្នកអើយ ឧសនាព្រៃអាយ អស់តែម្ល៉េះហើយ ឬមួយ នៅឡើយ អ្នកប្រាប់ខ្ញុំរ៉ា ។ ប្តីឆ្លើយរឹងទៅ មានច្រើនក្តាត់នៅ នាព្រៃព្រឹក្សា យកបានជារយ រទេះក្តីណា ពុំអស់ក្តីណា ពុំអស់ប្អូនភ្ងា នាងនឹងគិតថ្វី ។ នាងឮច្នោះណា អរឥតគណនា សំណេះនឹងប្តី ច្នោះអ្នកទៅរក យកមកទៀតខ្មី ឱ្យអស់ អំពី ព្រៃនោះហោង ។ នឹងជួលរទេះ ញាតិជិតនៅនេះ ដឹកទុកជាម្តង ប្តីថានាងនឹង យកឧសថ្វីផង បើអស់សឹមបង រក មកទៀតណា ។ ទើបនាងឆ្លាស់ឆ្លើយ ថាអ្នកប្តីអើយ ឈើនេះឈើជា សឹងមានតម្លៃ ក្លាំពាក់ក្រិស្នា អស់អ្នកភេត្រា គេ ទិញយកទៅ ។ ឈើនេះខ្ញុំស្គាល់ ជាក់ឥតពិភាល់ អស់អ្នកសំពៅ គេទិញមិនលែង ខ្ញុំឯងឃើញនៅ ។ ឈើនេះខ្ញុំ ស្គាល់ ជាក់ឥតពិភាល់ អស់អ្នកសំពៅ គេទិញមិនលែង ខ្ញុំឯងឃើញនៅ គេទិញនាំទៅ ស្រុកចិននាយណ៎ា ។ បើ យើងបានហើយ យើងគិតអ្វីឡើយ លក់តែក្រិស្នា ក្លាំពាក់ប្រពៃ យកថ្លៃមកណ៎ា ទិញព្រៃកាសាយ៍ សំពត់ជាតិ ។ តាម តែចិត្តជ្រើស ចិត្តនឹងស្រាល់រើស យកប្រាក់មាសក្តី ដោយចិត្តស្រឡាញ់ ចង់ទិញអ្វីៗ អ្នកទៅរឹងខ្មី តាមពាក្យខ្ញុំថា ។ ប្តីឮច្នោះនៃ អរឯងពេកក្រៃ ក្រទីក្រទា បានអម្រែកសង្រែក រែកទៅម្ទីម្នា ដឹងកាំបិតព្រា ចូលទៅក្នុងព្រៃ ។ កាត់គរទុក

ស្រេច ចង់ចោលជាបាច់ រ៉ែកមកពីថ្ងៃ ហើយប្រាប់ភរិយា ប្អូនអើយខុសថ្លៃ កាត់គរនៅព្រៃ ច្រើនក្រៃក្នាត់ណ៎ា ។ រ៉ែក មកនេះហោង តាមកម្លាំងបង ទើបនាងភរិយា រកជួលរទេះ ដឹកនាំក្រិស្នា ក្លាំពាក់ជាៗ ពីព្រៃនោះនៃ ។ គរទុកនាស្ថាន នោះហើយទើបមាន ពាណិជ្ជទីទៃ មកទិញក្រិស្នា ក្លាំពាក់ប្រពៃ នាងថ្លឹងកាត់ថ្លៃ ឥតល្មៀងឡើយណ៎ា ។ ហេតុនាង នារី ដឹងអស់អំពី កាលនាងនៅជា ប្រពន្ធនៃចៅ នាយភារភេត្រា ឥតឈ្មួញណាៗ បញ្ឆោតបានឡើយ ។ លុះឈ្មួញ ទិញបាន ពីនាងកល្យាណ គេយកទៅហើយ នាងរៀបទុកទ្រព្យ ផ្គួផ្គាប់ជាត្រើយ ពិតពុំលង់ឡើយ រណ្តាប់គ្រឹះស្ថាន ។ ចាយចាត់រៀបរក៍ លោះខ្ញុំកំដរ ប្រកបធនធាន អ្នកផងចេញចូល នាងសោតថ្កើងថ្កាន សម្បត្តិមូលមាន អនេក ទ្រព្យា ។ ប្តីនាងនេះនៃ បានស្គាល់ចៅទៃ ស្គាល់ព្រះស្គាល់ពញា អ្នកផងរាប់អាន ត្បិតបានទ្រព្យា កបនូវលក្ខណា នាងនោះប្រពៃ ។ ទើបនាងនារី ស្រដីនឹងប្តី ថាអ្នកសព្វថ្ងៃ ខ្ញុំចង់ឱ្យអ្នក រៀនរត់ឲ្យរ៉ៃ ឲ្យរួសឆាប់ក្រៃ ដូចចិត្តចិន្តា ។ ប្តី សោតឆ្លាស់ឆ្លើយ ថាហៃនាងអើយ បងឥតបើថា តាមចិត្តប្អូនហោង អញបងបានជា ម្ល៉េះត្បិតនរណា មិនត្បិតប្អូនស្រី ។ លុះថ្ងៃមួយណា នាងរៀបក្រយា សំណុំវេចខ្ចី ទឹកមួយបំពង់ នាងផ្ទង់ឱ្យប្តី ពុនរ៉ែករត់ខ្ចី សព្វៗវេលា ។ ដើមឡើយ រត់ហត់ ដង្ហើមផុតៗ ស្ទើរដាច់ខ្យល់ណា រត់វិលមកវិញ ប្រាប់ប្រពន្ធថា វាហត់ក្តាត់ណា ដូចនឹងស្លាប់ហោង ។ លុះ ដល់ពីថ្ងៃ ទើបរត់ទៀតរ៉ៃ ដោយចិត្តបំណង នឹងចង់ឱ្យបាន ដូចក្តីប៉ុនប៉ង ប្រាថ្នានោះហោង ចិត្តចង់សង្វាត ។ រត់ទៀត ដល់ទី ដើមកាលរត់ខ្ចី ដោយចិត្តខ្ចីឃ្នាត ត្បិតប្រពន្ធថា ចង់ចាំពុំឃ្លាត ខែងខំសង្វាត ដូចក្តីប្រាថ្នា ។ លុះប្តីនាងរត់ រត់ រួចពុំហត់ ដោយចិត្តសោះសា ឯនាងនារី យល់ប្តីអាត្មា បរិបូណ៌ហើយណា ទើបនាងឆាប់ក្រៃ ។ ទៅថ្កានមន្ត្រី ឱ្យគេ ថ្វាយប្តី ជាខ្ញុំក្សត្រថ្លៃ មន្ត្រីនាំថ្វាយ ដូចចិត្តនាងរ៉ៃ បម្រើសព្វថ្ងៃ ជាខ្ញុំរាជា ។

## បទភុជង្គលីលា

នឹងថ្លែងសម្តែងចរចា ឯមហាក្សត្រា ព្រហ្មទត្តធិបតី ។ សម័យមួយថ្ងៃចក្រី ឱ្យប្រាប់សេនីយ៍ សេនាពលផង ។ ត្បិតក្សត្រព្រហ្មទត្តជាច្បង មានព្រះបំណង ប្រពាតព្រឹក្សា ។ ឱ្យរៀបប្រុងប្រៀបបណ្តា ការកបយសា- ធិរាជស្តេច ស្តែង ។ ភ្នាក់ងារខ្មាន់ការតាក់តែង រៀបគ្រប់ដំណែង ដំណើរក្សត្រា ។ ឯចៅនោះនៅគ្រឹហា ប្រាយប្រាប់ភរិយា នាង អើយឥឡូវ ។ ព្រះបាទនរនាថឥតគូ ស្តេចតែងពលព្យូហ៍ ប្រពាតព្រឹក្សា ។ ចូរចៅប្អូនពៅពុំងារ ប្រដាប់ប្រដា ឱ្យបង ឆាប់ថ្វាត់ ។ នឹងទៅហែចៅចក្រវត្តិ ព្រះបាទព្រហ្មទត្ត ឥសូរសិរសា ។ នាងស្តាប់សាសព្ទប្តីថា នាងរៀបក្រយា ឲ្យប្តី ស្នេហ៍ស្នាល ។ អង្គសោតល្អត្រកាល អប់ផ្កាត្រកាល ប្រហើរឈ្ងុយឈ្ងប់ ។ អាហារត្រកាលសាយសព្វ រណ្តាប់គ្រាន់ គ្រប់ ឱ្យប្តីស្នេហា ។ រុំជាសំណុំហើយណា ផ្ទង់ជាក្រយា ស្ងោយមហាក្សត្រថ្លៃ ។ នាងដឹងដំណឹងនោះរ៉ៃ ថាក្សត្រទៅ ព្រៃ នឹងព្រាត់គ្នាគ្នី ។ នឹងឃ្លាតអាមាត្យមន្ត្រី មានប៉ុន្តែប្តី នាងនឹងពុនទៅ ។ ឯមហាក្សត្រចមចៅ ព្រឹកព្រាងច្រាលឆ្អៅ ប្រដាប់ព្រះអង្គ ។ ទ្រង់គ្រឿងរុងរឿងបញ្ចង់ ព្រះពស្ត្រទិព្វទ្រង់ ប៉ាក់ឆ្វាក់មាលា ។ ទ្រង់ស្រេចសម្តេចរាជា ស្តែងស្តេច យាត្រាឡើងលើអស្សតរ ។ ចេញទៅដល់ក្រៅនគរ ព្រះអង្គបើកបរ រជ្ជរាជអស្សពាហ៍ ។ ក្លំក្លស់ខ្ពង់ខ្ពស់សោភា ឆត្រ រួចជួរចា មរមាសរៀបរយ ។ អភិរម្យត្រសុំត្រសាយ ត្រសែតរំភាយ រំភើយសាក់សែង ។ សេនាយោថាខះខែង ករកាន់ លំពែង ហែៗច្រូងច្រាង ។ ដាវខែលក្រាស់ក្រែលសងខាង សេនាកាន់កាង ទួនទាំងចាមរី ។ មហាក្សត្រព្រហ្មទត្តចក្រី ឯកឯងពិសី ពាលពេញតលា ។ ដល់ក្នុងកំឡុងព្រឹក្សា ស្តេចអស្សពាហ៍ លឿនលន់កន្លង ។ សេនាយោធាពលផង

ខែងខំក្កាត់ហោង ពុំទាន់ក្សត្រា ។ ជិតដោយតាមក្រោយ អស្សពាហ៍ ប៉ុន្តែចៅមា -ណាពនោះឯងហោង ។ ត្បិតគាត់រត់ស្ទាត់កន្លង ទាន់ក្សត្រច្បាស់ច្បង ចមចក្ររាជា ។

## បទកាកគតិ

ព្រះបាទក្សត្រថ្លៃ ដល់ដើមព្រះជ្រៃ បញ្ឈប់អស្សពាហ៍ ព្រាត់មុខមន្ត្រី សេនីយ៍សេនា យល់តែចៅមា- ណាពនោះឯងហោង ។ ទើបក្សត្រចមចៅ ឈប់រង់យូរទៅ ពុំយល់មនុស្សផង ស្ដេចឃ្លានក្រយា ស្ងោយមហាក្សត្រហោង ត្រមោចកន្លង តែនឹងមាណពវា ។ ទើបព្រះព្រហ្មទត្ត ធិរាជចមក្សត្រ លើសលើលោកា សន្ទុតនាមនែ មាណពនោះណា ឱ្យហៅចៅមា យើងយសពណ្ណរាយ ។ ស្ដេចសព្វហាទ័យ ក្រសាលនៅនែ កំឡុងព្រៃនាយ ស្ដេចលីលាលេង ព្រឹក្សាពណ្ណរាយ សាន្តសុខសប្បាយ ទតព្រៃព្រឹក្សា ។ ស្ដេចត្រាច់ក្នុងព្រៃ ឥតអ្នកណានៃ នឹងទាន់ក្សត្រា សឹងរកក្សត្រថ្លៃ សព្វព្រៃព្រឹក្សា ខ្លាចខ្លួនក្កាត់ណា រកមិនឃើញឡើយ ។ រីឯព្រះបាទ ព្រហ្មទត្តនរនាថ លីលាឡើងហើយ បន្ទូលនឹងមា យើងថាចៅអើ ថ្ងៃពន់ពេកហើយ អង្គអញឃ្លានបាយ ។ ទន្ទឹងអស់គ្នា មន្ត្រីយោធា ចតុរង្គទាំងឡាយ សឹងតែពុំយល់ ផេ៍ពលព្រាត់ព្រាយ បែកផ្លូវខ្វាត់ខ្វាយ អស់ពុំយល់ណា ។ មាយើងទូលទៅ បពិត្រចមចៅ លើសលើលោកា បាយអញខ្ញុំមាន គឺមោះខ្ចីខ្នា ពុំគួរក្សត្រាធិរាជសោយសល់ ។ ស្ដេចស្ដាប់ហើយណា ថាយកមកប៉ា កុំគិតសល់រល់ ទោះល្អមិនល្អ ខ្មៅសតាមកល អញឃ្លានណាស់សល់ អត់ឯណាបាន ។ ទឹកតើញាំងចៅ បានសំចៃនៅ ឬមួយពុំបាន មាយើងទូលទៅ បពិត្រក្សត្រក្សាន្ត រីទឹកសោតមាន គឺមោះតែថា ។ ដាក់នឹងបំពង់ ពុំគួរព្រះអង្គ ស្ដេចសោយឡើយណា ស្ដេចស្ដាប់ថាទៅ យើងចៅកុំថា ច្នោះចៅម្នីម្នា យកមកឆាប់ៗ ក្សិណចៅមាយើង ម្នីម្នាដោះឡើង ទៅយកប្រដាប់ ដាក់ទឹកបំពង់ សំណុំបាយស្រាប់ ស្រេចស្រាយផ្ដូ ផ្គាប់ថ្វាយមហាក្សត្រា ។ ស្ដេចសោយអាហារ មាយើងត្រកាល មានរសពិសា បាយបរិសុទ្ធស អង្ករនោះណា ដូចព្រះក្រយា ស្ដេចសោយប្រក្រតី ។ អាហារពិសា គាប់ព្រះឱស្ឋមហា ក្សត្រក្សាន្តចក្រី បន្ទូលសរសើរ ថានេះមែនស្រី ប្រដាប់ចំណី ពិសេសពិសា ។ ប្រពន្ធមាយើង ចេះរៀបចុល់ថ្កើង មុខចៅមែនណា ចៅអើយអាហារ ត្រកាលពិសា សឹងជាតិឱជា រសត្រកាលក្រៃ ។ ជួនលើគម្លាន ឯណាមកមានអាហារក្នុងព្រៃ និងថាត្បិតឃ្លាន គូរពិសាក្រៃ មិនច្នោះឡើយនៃ ចំណីនេះជា ។ មាយើងបង្គំ មហាក្សត្រឧត្ដម ឥស្សូរសិរសា លុះស្ដេចសោយសល់ ស្កល់មហាក្សត្រា ស្ដេចសោយគង្គា បំពង់នោះនៃ ។ ទឹកសោតពិសា អប់អស់ក្លិនផ្កាពិដោរប្រពៃ ស្ដេចថាទឹកចៅ រសពិសាក្រៃ ឱនាងគាប់ចៃ ចេះរៀបឱ្យប្ដី ។ មាយើងនោះណា បង្គំក្សត្រា លើកដៃលមកឆី ឆីរួចស្កប់ស្កល់ បរិបូណ៌អស់ក្ដី ទើបព្រះចក្រី បន្ទូលទៅថា ។ ចៅមាយើងអើយ អញហូបបាយហើយ មិនចេះអត់ស្លា ចៅឱ្យចង់ចៅ មកឯអាយ៉ា អញនឹងស៊ីស្លា ឥឡូវនេះនៃ ។ ចៅមាយើងថ្វាយ ក្សត្រថ្លៃពណ្ណរាយ ដោយព្រះហប្ញទ័យ ស្ដេចសោយស្លាចៅ មាយើងនោះនៃ មានសព្វគ្រប់ក្រៃ ឥតខ្វះឡើយណា ។ ទាំងទេពទារូ ក្រវាញក្លាំពូ ស្លាខ្ចីសោតណា ក្រមួនមាត់ផ្ទង់ ព្រះអង្គសោយស្លា ហើយទើបត្រាស់ថា ស្លាចៅនេះនៃ ។ សព្វគ្រប់មានមិញ ដូចកលស្លាអញ តែងឆីសព្វថ្ងៃ ភព្វអញឯងហើយ ចៅអើយគាប់ចៃ អញបានអាស្រ័យ ចៅសព្វគ្រប់ហោង ។ បើអញបានដល់ ទីឋានមណ្ឌល ឯនាយហើយហោង អញឱ្យយសចៅ ជាធំកន្លង ចៅកម្សត់ផង អញអាសូរចៅ ។ បន្ទូលម៉្លោះហើយ ក្សត្រាត្រាណត្រើយ ព្រះផ្ទំលើភ្លៅ មាយើងហើយថា ចៅអើយនៃចៅ ស្ដាប់អញនិងនៅ និយាយមួយហោង ។ ស្ដាប់ណាចៅអាយ ដំណើរនិយាយ ព្រេងព្រឹទ្ធកន្លង អញនៅថ្លាថ្លែង សំដែងទំនង និទានមួយហោង ពីព្រេងអតីតា

។ ពុំទាន់និយាយ ដំណើរអភិប្រាយ សណ្ដាប់ដល់មា យើងស្ដេចផ្ទំលក់ សាន្តសុខមហិមា ក្រោមដើមនៃមហានិគ្រោធនោះនៃ ។ រីកាលនោះណា មែនមានទេវតា រក្សាព្រះជ្រៃ ឮព្រះព្រហ្មទត្ត មហាក្សត្រជៀស្នជ័យ ស្ដេចបន្ទូលរ៉ៃនឹងមាយើងថា ។ ស្ដេចនឹងនិយាយ ទេពតាទាំងឡាយ បបួលគ្នីគ្នា មកមីរលើជ្រៃ ស្ដាប់សព្ទក្សត្រា យល់ស្ដេចនិន្ទ្រាពុំបន្ទូលទៅ ។ ទេពតាខឹងក្ដាន់ នឹងព្រះព្រហ្មទត្ត ធិរាជចមចៅ ថាក្សត្រនេះណា មុសាក្រៃក្រៅ ពោលពាក្យអាសៅ ពុំកាន់ពាក្យសត្យ ។ ច្នោះយើងអត់ថ្វី ស្ដេចពោលអប្រិយ កាច់មែកជ្រៃថ្វាត់ ទម្លាក់លើ សង្កត់មហាក្សត្រ ឲ្យស្ដេចបង់បាត់ ព្រះជន្មជីវី ។ ថាបើពុំទាន់ នៅនេះក្រៃខាន ស្ដេចទៅបុរី យើងកាច់ខ្លោងទ្វារ សង្កត់ចក្រី ព្រហ្មទត្តត្តិរ្ថិយ ឱ្យក្ស័យជន្មា ។ ថាបើបានទៅ លុះស្ដេចចូលទៅ ដល់លើក្រឡា បន្ទំរម្យរ័តន៍ តែស្វាត់និទ្រា យើងប្រែក្រឡា ជាពស់ទៅខាំ ។ ស្អប់ស្ដេចកុហក ថាហើយដេកលក់ ឱ្យតែយើងចាំ មាយើងងងុយ អង្គុយតែចាំ ឮពាក្យងុំៗ ង៉ាៗនោះណា ។ មាយើងដាស់ស្ដេច ឆាប់មួយរំពេច ទើបទូលទៅថា បពិត្រស្ដេចឡើង ជវនអស្សា ឆាប់ៗម្ទីម្នា ឥឡូវនេះនៃ ។ ត្បិតមានទេវតានិត្យនៅរក្សា លើដើមព្រះជ្រៃ ខឹងថាស្ដេចនឹង និយាយហើយនៃ ផ្ទំលក់រឹងរ៉ៃ ស្ងៀមស្ងាត់ភាសា ។ ខ្ញុំចាំស្ដេចផ្ទំ រលើវទៅខ្ញុំ ឮពាក្យទេពតា ស្ដេតស្ដាប់មាយើង ស្ទុះឡើងអស្សពាហ៍ បំផាយម្ទីម្នា មាយើងដោយដិត ។ ក្សិណមែកព្រះជ្រៃធ្លាក់ផុតក្សត្រថ្លៃ ព្រះបាទព្រហ្មទត្ត ស្ដេចទៅរំលង ពីភ័យមរណថ្វាត់ ទើបមាយើងគិត ទូលទៅទៀតថា ។ បពិត្រព្រះភូ ធររាជឥសូរ នេះមួយគ្រា មួយទៀតខ្ញុំឮ ពាក្យអស់ទេពតា ថាដល់សីមា ព្រះអង្គនាយនោះ ។ នឹងកាចខ្លោងទ្វារសង្កត់ភូបាល រឹងវិញទៀតស្មោះ ថាបើកន្លង រំលងពីនោះ លុះព្រះអង្គឆ្ពោះ ចូលក្នុងបន្ទំ ។ និងប្រែកាឡា ជាពស់មហិមា ខាំក្សត្រាឧត្ដម ទេពតាជំនុំ ដូច្នោះនេះខ្ញុំ ឮជាក់ជាម្ដង ។

## បទពំនោល

មហាក្សត្រព្រហ្មទត្តច្បាស់ច្បង ស្ដេចស្ដាប់ទំនង ទំនួលនៃចៅមាយើង ទើបមហាក្សត្រថ្កល់ថ្លើង ថាច្នោះមាយើង ប្រយ័ត្ននូវខ្លោងទ្វារនោះ ។ ចៅកាន់រំពាត់វាត់គោះ ចៀសជួយតឿនស្មោះ ឱ្យរួចពីភ័យទ្វារធំ ។ ស្ដេចមានហឫទ័យបារម្ភ បរសេះខែងខំ លុះទៀបនៃខ្លោងទ្វារនោះ ។ ក្សត្រថ្កើងមាយើងវាត់គោះ សេះសោតលោតផ្លោះ ច្រៀវច្រូចគ្រលួចមហិមា ។ បាក់ខ្លោងទ្វាររាជសីមា ផុតមហាក្សត្រា ក៏រួចរំលងពីភ័យ ។ លុះដល់មណ្ឌលទិព្វថ្លៃ ចៅមាយើងរ៉ៃ ក្រាបលាទៅថ្កានគ្រឹះឋាន ។ ព្រះបាទព្រហ្មទត្តទ្រង់មាន បន្ទូលផ្ដាំថ្កាន ថាចូលចៅទៅហោងណា ។ ហើយចៅវិលវិញយាត្រា មកឆាប់ម្ទីម្នា ចៅចាំដូចចៅឮហោង ។ មាយើងក្រួញក្រាបទូលស្នង បពិត្រនេះម្ដង កុំព្រួយព្រះរាជហឫទ័យ ។ បានទៅនៅវិលរឹងរ៉ៃ ចាំក្សត្រជៀស្នជ័យ ដ៏ជាមកុដសិរសា ។ ទូលស្រេចមាយើងម្ទីម្នា មកផ្ទះអាត្មាប្រាយប្រាប់ភរិយាអស់ក្ដី ។ ដំណាលប្រាប់កាលចក្រី ព្រាត់មុខមន្ត្រី ទៅផ្ទំក្រោមដើមព្រឹក្សា ។ ប្រាប់ពីស្ដេចសោយក្រយា សរសើរនាងថា ភរិយាបានចេះស្ងួនគ្រង ។ ប្រាប់អស់ដំណើរទំនង នាងត្រេកអរផង ត្បិតបានដូចចិត្តចិន្ដា ។ មាយើងនោះនិងភរិយា ហូបបាយហើយណា ក៏កាន់ដាវឡើងទៅចាំ ។ អង្គុយជិតនៅគយឃ្លាំ ក្នុងចុងរោងរាំ ព្រះបាទសម្ដេចព្រហ្មទត្ត ។ មន្ត្រីក្រាស់ក្រៃច្រើនក្ដាន់ ប្រុងប្រាណប្រយ័ត្ន ដ៏ពេញនៅរាជរោងរម្យ ។ លុះដល់អធ្រាត្រដាស់ទំដេកស្ងាត់ជ្រងំ ពុំភ្ញាក់ដល់ម្នាក់ឡើយណា ។ កាលនោះឯងឯទេវតា ប្រាណប្រែកាឡា ជាតិជាពស់វារទៅហោង ។ ទំហំពស់ធំកន្លង ប៉ុនដើមត្នោតផង ក៏លើកពពារគួរខ្លាច ។ មានភ្នែកនោះធំត្រដាច ចង្កូមសស្វាច នឹងខាំព្រះមហាក្សត្រា ។ មាយើងដោះឡើងម្ទីម្នា លើកខាន់មុតថ្លា ក៏វាត់ត្រូវសិរសាសល់ ។ ឈាមពស់ខ្វាត់ខ្វាយទៅដល់ ទេពីនិមល

ក៏ពេញនាព្រះថនា ។ ទើបហៅមាយើងគិតថា ពស់នេះមរណា អសារសោះសូន្យជីវី ។ ឈាមដូចដល់ព្រះទេពី វររ័តន៍ក្សត្រី ច្នេះតើនឹងធ្វើម្ដេចបាន ។ ជ្រះឈាមពីនាងកល្យាណ នឹងដាស់ក្សត្រក្សាន្ត យល់ក្តីពុំគួរក្តាត់ណា ។ នឹងយកដៃជូតឱ៉ា សោតសឹងពុំជា កើតក្តីពុំគួរពេកក្រៃ ។ ទើបយកខ្មោចពស់នោះវ៉ៃ ដាក់នៅក្រោមពូ ក្រឡាបន្ទំរម្យរ័តន៍ ។ ស្រេចហើយទើបកាត់ហាវមាត់ លិទ្ធឈាមដែលដិត នៅនាព្រះស្គន់ក្សត្រី ។ នាងនាថភ្ញាក់ឥន្ទ្រិយ៍ ទើបដាស់ភូមី ដ៏ជាគម្ដែងក្រឡា ។ នាងខ្សឹបប្រាយប្រាប់ថាមា យើងយកជីវ្ហា មកលិទ្ធនូវដោះខ្ញុំហោង ។ ស្ដេចស្ដាប់ក្រោធក្រៃកន្លង ត្រាស់ប្រើពលផង ថាម្នាលពេជ្ឈឃាដម្ទីម្នា ។ ចូរឆាប់ចាប់ចងយកវា កំណាចមហិមា នេះនាំយកទៅសម្លាប់ ។ ក្សិណនោះពេជ្ឈឃាដចូលចាប់ ចងមាយើងខ្ជាប់ ក៏នាំយកទៅម្ទីម្នា ។ ហេតុស្ដេចឥតពិចារណា ពុំគិតគុណមា យើងយកតែពាក្យទេវី ។ ពេជ្ឈឃាដនាំទាំងរាត្រី ទៅបូព៌ទិសទី ក៏ថានឹងអ្នកនាយទ្វារ ។ ឱ្យបើកត្បិតព្រះភូបាល មានព្រះឱង្ការ ឱ្យនាំអ្នកទោសទៅកាប់ ។ ក្សិណនោះនាយទ្វារស្ដែងស្ដាប់ យល់ខុសនិងច្បាប់ សម្លាប់អ្នកទោសទាំងយប់ ។ ថាទោសនេះម្ដេចអ្នកឈប់ ប្រាយប្រាប់សព្វគ្រាប់ ដំណើរដំណាលសេចក្តី ។ នាំអ្នកទោសទាំងរាត្រី ពុំត្រូវច្បាប់ពីបុរាណគន្លងឡើយណា ។ ពេជ្ឈឃាដឆ្លាស់ឆ្លើយរឹងថា អញដឹងឯណា ជាទោសធ្ងន់ស្រាលអ្វីៗ ។ ស្ដេចប្រើអញទាំងរាត្រី ចៅមករកក្តី លើព្រះបម្រើម្ដេចបាន ។ អំណាចអ្វីៗឯងមាន ក៏អញនឹងហ៊ាន នាំគេមកសម្លាប់លេង ។ អម្បាលចៅយើងឯង ម្ដេចពុំកោតក្រែង ក៏ទាស់ព្រះរាជអាជ្ញា ។ នាយទ្វារសោតឆ្លើយរឹងថា បើព្រះអាជ្ញា លុះត្រូវនឹងច្បាប់ ទើបបាន ។ បើខុសនឹងច្បាប់បុរាណ យើងឃាត់ខាំងខាន បានត្បិតយើងជានាយទ្វារ ។ បើយើងក្រាបទូលនាកាល នោះព្រះភូបាលនឹងធ្វើម្ដេចៗ តាមកល ។

### បទកាកគតិ

នាយទ្វារនោះណា បង្ហានអាជ្ញា ឈរឈប់រចល់ ទើបនាំនិទាន មែនមានមនុស្សសល់ ប្រាយប្រាប់អស់កលនឹងពេជ្ឈឃាដហោង ។ ចៅអើយនិយាយ កាលពីព្រេងនាយ ទុកជាទំនង មុនមានស្រីម្នាក់ មានកូនមួយហោងចិញ្ចឹមស្គាវផង ស្រឡាញ់រក្សា ។ ស្រីនោះទៅផ្សារ ទុកនៅតែស្គាវ និងកូននោះណា ផ្ដេកក្នុងអង្រឹង ទើបចរយាត្រាក្រោយនោះពស់អា- សិរពិសយង់ឃ្នង ។ ក្សិណពស់លលាំ វារមកចឹកខាំ កូននោះមរណហោង ស្គាវយល់ពស់ពិសទ្រុស្ដទ្រឹស្តិកន្លង ស្គាវប្រខាំផង នឹងពស់នោះណា ។ កាលនោះពស់ ពាលប្រខាំនឹងស្គាវ ស្គាវខាំមរណា ម្ចាស់មកពីផ្សារក្សិណស្គាវនោះវា រត់ដោយមាគ៌ា ទៅទទួលហោង ។ រីស្រីម្ចាស់ស្គាវ យល់ឈាមរន្ទាល នៅខ្លួននោះផងប្រមាណគិតថា ស្គាវកាចកន្លង ខាំកូនជាម្ដង មិនឈាមអ្វីឡើយ ។ ខឹងឆុលឆៀបឆាប់ វាយស្គាវសម្លាប់ បោះបង់សៀតហើយ ចូលទៅមើលកូន ឃើញសូន្យឥត ត្រើយ ពិតពុំទេឡើយ យល់ពស់មរណា ។ ទើបគិតឯងយល់ ថាពស់កាចសល់ ខឹងខាំបុត្រភ្ងា ស្គាវការបុត្រនោះ ប្រខាំសោះសា យល់ស្នាមជាក់ជា បន្ទាល់ទៀងពិត ។ ទើបគិតស្ដាយស្គាវ ស្ដាយកូនសង្សារ សោះសូន្យជីវិត សោកឯងផ្សាឯង ស្ដាយអស់ពីចិត្ត អញខ្លាចមហាក្សត្រ នឹងស្ដាយច្នោះហោង ។ ហេតុនេះអញពុំ បើកបើខឹងខំ ខុសច្បាប់កន្លង ចៅទៅទ្វារទៀត រីអញនេះម្ដង មិនបើកឡើយហោង និយាយសោតមាន ។

ពេជ្ឈឃាដស្ដាប់ហើយ ខំពុំបានឡើយ ទើបនាំទៅថ្កាន នាយទ្វារទក្សិណ ឱ្យបើកត្បិតមាន ព្រះបន្ទូលថ្កាន ប្រើយើងនេះណ៎ា ។ នាំមនុស្សទៅកាប់ ចៅបើកឆាប់ៗ ដូចព្រះអាជ្ញា នាយទ្វារទក្សិណ នោះសោតឆ្លើយថា លោកដែល

ឯណា នាំទាំងរាត្រី ។ ពេជ្ឈឃាដឆ្លើយថា ព្រះអើយអញណា ប្រកែកថាអ្វី បើកទៅឆាប់ៗ នឹងកាប់ម្នាម្នី នៅទាស់សេចក្តី លើព្រះអាជ្ញា ។ យើងនេះមិនព្រាង កុំចៅអួតអាង ឃាត់ខាំងរាំងរា បើចៅមិនជឿ ទៅទូលក្សត្រា យើងពុំមុសាវាទវៀចឡើយហោង ។ នាយទ្វារឆ្លើយថា ជឿជាក្សត្រា ប្រើជាក់មែនហោង នាំទៅសម្លាប់ តែច្បាប់សព្វដង សម្លាប់មនុស្សផង សឹងនាំទៅថ្ងៃ ។ នេះនាំទាំងយប់ យើងនឹងឱ្យឈប់ លុះស្រាងឧទយ បើចៅនឹងខំ យើងពុំបើកវ៉ៃ ច្បាប់យើងទីទៃ ចេះចាំស្នាត់នៅ ។ ហើយមាននិយាយ អំពីព្រេងនាយ អញនឹងប្រាប់ចៅ ចៅស្តាប់អញថ្លែង សំដែងសំដៅដោយនិទានទៅ ដំណើរអតីតា ។ មុនមានសេដ្ឋី មានទ្រព្យប្រាំបី កោដិឃ្លាំងសោះសា ចិញ្ចឹមឆ្កែចាំ ឆ្កែប្រាំរយណាសឹងឆ្កែជាៗ បានដូចនូវចិត្ត ។ ទោះមនុស្សជាចោរ ឃើញតែស្រមោល បណ្តេញដោយដិត ព្រួសព្រមនឹងខាំ ប្រចាំគ្នាស្នាត់ រក្សាសម្បត្តិ នៃមហាសេដ្ឋី ។ សេដ្ឋីនេះណ៎ា សឹងឱ្យរក្សា ឆ្កែជាប្រក្រតី មានខ្ញុំដណ្តាំបាយឱ្យឆ្កែផី សព្វទិនរាត្រី ពុំសោះឡើយណា ។

មានកាលមួយថ្ងៃ ចោរប្រាំរយវ៉ៃ គប់គិតនឹងគ្នា វាជីកឧម្មង្គឡើង លួចទ្រព្យមហា សេដ្ឋីនោះណា អស់ពីឃ្លាំងហោង ។ ឆ្កែប្រាំរយយល់ គ្រជូរដេញដល់ ព្រមព្រួសខឹងខ្លាំង ដេញក្នុងឧម្មង្គ ក្នុងឋានកំបាំង ខាំចោរស្លាប់ទាំង ប្រាំរយអស់វ៉ៃ ។ លុះព្រឹកសេដ្ឋី យល់ទ្រព្យបាត់ពី មណ្ឌលឃ្លាំងជ័យ ប្រាំមួយកោដិគត់ អស់ឥតសង្ស័យ សេដ្ឋីក្រោធក្រៃថាអេះអសារ ។ ចិញ្ចឹមឆ្កែថ្វី ឱ្យបាយវាឆី វាដេកឥតការ ចោរលួចទ្រព្យអស់ ឆ្កែពេញទាំងវាល ឥតសព្វឥតសារ នឹងទុកថ្វីវា ។ សេដ្ឋីឱ្យចាប់ ឆ្កែទៅសម្លាប់ ឥតសំណល់ណា លង់លុះខ្មោចចោរ ធុំក្លិនដល់មហា សេដ្ឋីនោះណ៎ា ដ៏ជាម្ចាស់ទ្រព្យ ។ សេដ្ឋីថាយើ អស់ក្មេងនេះតើ យកឆ្កែទៅកាប់ ត្រង់ឋានឯណា វាស្អុយស្មើរស្លាប់ ទៅយកឆាប់ៗ អូសចេញឱ្យឆ្ងាយ ។ ខ្ញុំមហាសេដ្ឋី ប្តឹងប្រាប់រឹងខ្មី ថាឆ្កែទាំងឡាយ យើងខ្ញុំសម្លាប់ កណ្តាលព្រៃឆ្ងាយ មិនធុំដល់អាយ នេះឡើយម្ចាស់ថ្លៃ ។ ទើបមហាសេដ្ឋី ថាដូច្នោះខ្មោចអ្វី ធុំស្អុយពេកក្រៃ អារកហិតមើល ប្លែកក្រៃវិស័យខ្ញុំនោះវ៉ៃ ។ ហិតរកហោងណា ។ ដល់មាត់រណ្តៅ នោះធុំស្អុយក្រៅ វិស័យសោះសា ខ្ញុំនោះវិលមក ប្រាប់សេដ្ឋីថា រណ្តៅមួយណា ធុំស្អុយពេកសល់ ។ ទើបសេដ្ឋីថា បើដូច្នោះអស់គ្នា ទៅជីកឱ្យយល់ ក្សិណខ្ញុំសេដ្ឋី កាន់ចបរចល់ ជីកទៅយង់យល់ ខ្មោចចោរមរណា ។ របួសទៀតទេ សឹងចង្កូមឆ្កែ នោះគ្រប់អស់គ្នា ទ្រព្យក្នុងឧម្មង្គ សឹងគង់នៅជា អស់ខ្ញុំនោះវា មកប្រាប់សេដ្ឋី ។ សេដ្ឋីគន់គិត តែក្នុងគំនិត ដឹងដើមសេចក្តី ថាអេះអញឆ្លោយ ឯងឱ្យសម្លាប់ ឆ្កែនោះពុំគាប់ ខុសទៅហោងណា ។

ចៅអើយមហាក្សត្រ ព្រះបាទព្រហ្មទត្ត លើសលើលោកា អញថានឹងឆ្លោយ ស្តាយក្រោយដូចមហា សេដ្ឋីនេះណា មិនលែងឡើយហោង ។ អញពុំបើកចៅ ចៅនាំយកទៅ ទ្វារឯទៀតផង ទ្វារអញមានច្បាប់ ចេះស្រាប់កន្លង អញពុំបើកហោង កុំបង្ខំអញ ។

ពេជ្ឈឃាដនោះស្តាប់ អស់អាថ៌សារសព្វ នោះទើបនាំចេញ ទៅទ្វារបស្ចិម កាលគ្រានោះវិញ អ្នកទ្វានោះមិញ ពុំបើកឡើយហោង ។ ពេជ្ឈឃាដថាបើ ចៅពុំបើកតើ មានច្បាប់ទំនង ដំណើរនេះម្តេច ចូរចៅសាសង ប្រាយប្រាប់អញហោង អស់អាថ៌សារសព្វ ។ ទើបអ្នកទ្វារថា លោកដែលឯណា នាំមនុស្សទៅកាប់ ទាំងយប់រាត្រី ខុសពីក្បួនច្បាប់ ចៅអើយចូរស្តាប់ និយាយអញមាន ។ មុនមានមហាក្សត្រ សោយរាជ្យសម្បត្តិ សម្បូរធនធាន ចិញ្ចឹមសេកសត្វ សេករតន៍កល្យាណ ហើយទៅហិមពាន្ត រកភស្តុចំណី ។ សេកមានសម្បុរ នោះល្អនិមល កបបញ្ចិន្ទ្រិយ កាលនោះស្តេច

យល់ សម្បុរបក្សី សេកស្ទួគ៌សោភា ល្អល្អះប្រពៃ ។ ស្តេចអរកន្លង បន្ទូលទៅផង សេកស្ទួគ៌នោះវ៉ៃ សេកអើយសម្បុរ អ្នកយល់ល្អក្រៃ ហេតុម្តេចចូរលៃ លកប្រាប់អញវ៉ា ។ សេកសោតទៀតទូល បពិត្រឥសូរ ជាមកុដសិរសា សម្បុរខ្ញុំល្អ ត្បិតខ្ញុំភោក្តា ផ្លែស្វាយនៅនា ព្រៃព្រះហិមពាន្ត ។ រីស្វាយនេះណា បើចាស់ជរា អាក្រក់ប៉ុន្មាន បានបរិភោក្តា ផលានោះក្សាន្តក្សិណ នោះប្រែប្រាណ កំលោះរឹងវ៉ៃ ។ ស្តេចស្តាប់សាសត្យ សេកស្ទួគ៌ទូលថ្វាត់ បន្ទូលថាហៃ សេកអើយ បើច្នោះ អ្នកទៅឆាប់វ៉ៃ ពាំនាំពីព្រៃ ផ្ញើយើងនឹងឆី ។ សេកសោតទទួល ព្រះបន្ទូលស្រួល ស្រុះស្រេចអស់ក្តី ហើយហើរ ផ្លេកផ្លោះ ទៅស្មោះឃ្មាតខ្មី រកភស្តុចំណី ចំណង់ភោក្តា ។ លុះនឹងវិលថ្កាន ទើបសេកពាំបាន មួយនោះណា មកផ្ញើ មហាក្សត្រ ស្តេចអរក្តាត់ណា ទទួលផល្លា ពីបក្សីសត្វ ។ ស្តេចគិតថាស្វាយ នេះតិចអម្បាយ បានពីរបីម៉ាត់ បើអញ នឹងឆី ឱ្យល្អខ្លួនថ្វាត់ តែអញឯងក្សត្រ នូវបុត្រភរិយា ។ និងញាតិទាំងឡាយ បើច្នោះយកស្វាយ នេះទៅដាំនា ឋាន មួយបើដល់ បានផលព្រឹក្សា សឹមយើងនាំគ្នា ឆីឱ្យហោង ។ នឹងមានរូបរ័តន៍ ប្រពៃល្អក្តាត់ ពេកពន់កន្លង ទើបស្តេច បណ្តុះ ស្វាយនោះជាម្តង ដុះដូចស្តេចប៉ង បំណងប្រាថ្នា ។ ស្តេចឱ្យទៅដាំ មានអ្នកផងចាំ ពិភ័ក្តិរក្សា លុះស្វាយនោះ ធំ បានផលផ្លែផ្កា ហេតុដាំនោះណា លើរន្ធនាគនៃ ។ ពិសនាគសព្វសាយ ជ្រួតជ្រាបផ្លែស្វាយ ពិសពស់វិស័យ លុះ ស្វាយនោះធំ ទើបក្សត្រជៀស្ទជ័យ ឱ្យបេះច្រើនក្រៃ យកមកហោងណា ។ ស្តេចឱ្យអមាត្យ ជំនិតព្រះបាទ ឆីមុនក្សត្រា អមាត្យនោះឆី ពុលពិសមរណា នៅព្រះភក្រ្តមហា ក្សត្រក្សាន្តនោះវ៉ៃ ។ ស្តេចយល់អមាត្យ ពុលពិសសល់ខ្មាត ទ្រង់ ព្រះក្រោធក្រៃ ពុំពិចារណា ឡើយមហាក្សត្រថ្លៃ ថាសេកចង្រៃ នឹងសម្លាប់អញ ។ ភ័ព្វអញនេះម្តង អញឱ្យឆីលង មើលមុនមែនមិញ បើអញឆីឯង ឥតក្រែងសមអញ អស់ជីវិតវិញ មិនលែងឡើយណា ។ ស្តេចខ្ញាល់ឆុរឆាប់ វាយ សេកសម្លាប់ ឥតពិចារណា ដំណពីនោះ ស្វាយនោះផ្លែផ្កា ឥតនរណា នឹងហ៊ានបេះឆី ។ លុះចំណរទៅ នាគនោះ និត្យនៅ ពុំបានថយពី លំនៅនោះចេញ ពិសពេញធរណី ប្រែជាសាបខ្មី ពុំពុលឡើយណា ។ អង្វែងទៅណាស់ តា ចាស់ដូនចាស់ ពិបាករក្សា ដំរីមហាក្សត្រ មកគិតគ្នាថា យើងនេះជរា ចាស់ណាស់ទៅហើយ ។ ទន្ទឹងតែស្លាប់ វាមិន ឆាប់ស្លាប់ ដូចចិត្តសោះឡើយ បើច្នោះយើងរស់ ជាមនុស្សថ្មីអើយ ពិបាកឥតត្រើយ មកយើងទៅឆី ។ ស្វាយដែល ស្តេតដាំ ឱ្យស្លាប់ទៅចាំ រស់រូបធ្វើអ្វី ពិបាកអាត្មា រក្សាដំរី គាត់គិតព្រមប្តី ប្រពន្ធហើយទៅ ។ បេះបានមកឆី ក្សិណ នោះឯប្តី ប្រែសក់ជាខ្មៅ សម្បុរជាក្លោះ4 ឥតខ្ទោះហ្មងសៅ ក្រឡេកមើលទៅ ប្រពន្ធនោះណា ។ ប្រែជាក្រមុំ សម្បុរគួរ សម ដោះដូចបទុមា ប្តីថានាងល្អ នាងមកពីណា ប្រពន្ធឆ្លើយថា យើងប្លែកអញហើយ ។ ប្តីព្នភរិយា ចាំតែពាក្យថា មុខមិនស្គាល់ឡើយ ទើបឆ្លើយទៅថា ឱលាភអញអើយ ពាក្យប្រហែលហើយ រូបរាងទីទៃ ។ ប្រពន្ធឆ្លើយថា ព្រះអើយ អញណា ខ្លាវង្វេងព្រៃ ក្រពើវង្វេង បឹងឯងសព្វថ្ងៃ នរណាឡើយ នៃ អញឯងដូនចាស់ ។ ចៅឯងសក់ស ខ្នងកោងមិន ល្អ ឥឡូវប្រែផ្លាស់ ជាសក់ខ្មៅញាប់ ចំណាប់ធំណាស់ មុនមិញសោត ចាស់ ឥឡូវកំលោះ ។ ប្តីថាយ◌ីអើ ឱ្យស្លាប់មិ ញតើ មកឆីស្វាយនោះ ម្តេចអញនឹងមេ ប្រែខ្វៃងជាក្លោះ មេអើយបើច្នោះ ជាភ័ព្វយើងឯង ។ ដូនតាប្រែប្រាណ ស្រេច វិលរឹងថ្កាន លំនៅឥតក្រែង រក្សាដំរី ដូចពីមុនព្រេង ដោយជាអញឯង ពិតពុំឃ្លាតឃ្លា ។ កាលនោះស្តេចយល់ កំលោះ និមលរូប រាងសោភា ស្តេចត្រាស់ដណ្តឹង ថាមនុស្សពីណា មកនៅរក្សា ដំរីអញហោង ។ ទើបតាកំលោះ ទូលទៅតាម ស្មោះ បពិត្រច្បាស់ច្បង ខ្ញុំគឺតាចាស់ នៅនោះឯងហោង ត្បិតឆីស្វាយផង ប្រែប្រាណច្នេះណ៎ា ។ ស្តេចស្តាប់ថាយើ ស្វាយពុលមិញតើ ម្តេចប្រែជា ច្នេះចូរអ្នកផង ទៅបេះម្ទីម្នា យកមកឆាប់វ៉ា អញនឹងឱ្យឆី អាមាត្យក្រាបលា ទៅបេះ ម្ទីម្នា យកមកឆាប់វ៉ា អញនឹងឱ្យឆី ។ អាមាត្យក្រាបលា ទៅបេះផល្លា មកថ្វាយភូមី ទើបស្តេចឱ្យអា- មាត្រមុខមន្រ្តី ឆី

មុនចក្រី ចង់ដឹងអក្ខរា ។ អាមាត្យមួយឆី ល្អអស់ឥន្ទ្រិយ ប្រពៃសោភា ស្ដេចយល់ច្នោះរ៉ៃ ព្រះទ័យសង្កា ត្រាស់ប្រើឱ្យមហា មាត្យមួយឆីទៀត ។ រ៉ែងល្អនិមល ស្ងួរសមសម្បុរ ទ្បើងដូចរមៀត ស្ដេចត្រាស់ឱ្យអា មាត្រមួយឆីទៀត ទើបស្ដេចបានបៀត ទ្រង់នឹងព្រះហស្ដ ។ ឯងឱ្យបុត្រី បុត្រាមហេសី ទ្រង់សោយទាំងអស់ សឹង មានព្រះអង្គ នោះប្រែប្រាណផ្លាស់ ចាកចោលឯចាស់ ក្រឡះបានជាពាល5 ។ ស្ដេចយល់ច្នោះហើយ ទើបក្សត្រត្រាណត្រើយ សោយផលអាហារ ល្អអស់ព្រះអង្គ រុងរឿងត្រកាល សម្ដេចភូបាល ប្លែកនឹងសព្វគ្រា ។ ទើបក្សត្រជៀស្មជ័យ គិតក្នុងព្រះទ័យ អង្គីក្ដីណា ហេតុអ្វីស្វាយពុល បានប្រែជាៗ ស្ដេចត្រាស់ឱ្យអា មាត្យមើល អស់ក្ដី ។ អាមាត្យទៅមើល រណ្ដៅនោះឃើញនាគនៅអំពី មុនមានដូច្នោះ ទើបទូលចក្រី ស្ដេចមានព្រះពិ ចារណាយង់យល់ ។ ជាពស់នាគា ជ្រួតជ្រាបព្រឹក្សា ពិសពស់អស់កល ពីមុននាគមិញ ពិសពេញសព្វសល់ អញឯងដាលដល់ សម្លាប់សេកសត្វ ។ ស្ដេចសែននឹកស្ដាយសេកស្ងួគ៌ពណ្ណរាយ អសារបង់បាត់ នៃចៅពេជ្ឈឃាដ ព្រះបាទព្រហ្មទត្ត អញខ្លាចមហាក្សត្រ នឹកស្ដាយក្រោយក្រៃ ។ ហេតុច្នោះឯងអញ ពុំបើកចៅចេញ ទៅទាំងយប់រ៉ៃ បើទោសខ្លាំងសល់ ចៅចាំដល់ថ្ងៃ ច្បាប់មានក្សត្រថ្លៃ នឹងខ្វាល់ពុំបាន ។

ពេជ្ឈឃាដស្ដាប់ស្ដែង នាយទ្វារសំដែង ដំណាលនិទាន ទើបទៅឯទ្វារ ឧត្ដរទីឋាន ពេជ្ឈឃាដហៅហានស្រែកប្រាប់ទៅថា វ៉ឺយអស់នាយទ្វារ រក្សាសព្វកាល បើកអញម្ទីម្នា ត្រាស់ប្រើអញនាំ អ្នកទោសនេះណា6 ទៅកាប់សោះសា ចៅបើកអញឆាប់ ។ នាយទ្វារឆ្លើយទៅ ថាចៅវ៉ឺយចៅ មិនដែលមានច្បាប់ នាំអ្នកទោសទៅ ទាំងយប់សម្លាប់ អញយល់ពុំគាប់ ខុសព្រះមាត្រា ពេជ្ឈឃាដខឹងខំ ថាម្ដេចក៏ពុំ បើកព្រះអាជ្ញា ឃាត់អញអើភាន ឯងមានច្បាប់ណា ឱ្យឯងរាំងរា លើព្រះបម្រើ ។ នាយទ្វារឆ្លើយទៅ ថាពេជ្ឈឃាដចៅ ងារអញឯងបើ អញឃាត់ម្ល៉េះខុស ច្បាប់ដូច្នោះតើ ចៅខឹងខំប្រើ ឱ្យបើកទៅបាន ។ អញជានាយទ្វារ ពីមេពីបា រឿងពីបុរាណ មិនដែលឮថា ដូច្នោះនឹងមាន បើទោសប៉ុន្មាន ក្សត្រមានបុណ្យថ្កើង ។ ប្រើនាំទៅផ្គង ចៅនៅនេះហាង ទម្រាំព្រឹកទ្បើង សឹមនាំចេញថ្វាត់ យើងឃាត់តាមរឿង បើផ្គងទោសយើង សឹងមានគ្រប់គ្នា ។ យល់តែស្ដេចប្រើ យើងបើកហើយតើ មិនខុសមាត្រា ដំណានឹងឃ្លៀងលំអៀងច្បាប់ប្រា- កដកើតអនា ទរ7ផ្ទៃក្រោម8ក្រៃ ។ ស្រដីរាជការ ដោយមុខភ្នាក់ងារ កាន់ខ្ជាប់ទីទៃ យល់តែអំណាច ល្មមខ្លាចៗក្រៃ បើពុំល្មមនៃ ទាស់សិនដោយច្បាប់ ។ មុខមន្ត្រីធំ បើបានជំនុំ ព្រមប្រើសម្លាប់ ឮតែក្សត្រា ពុះពារប្រើកាប់ ក្រោធក្រៃឆុរ ឆាប់ នឹងព្រះអំណាច ចៅអើយច្បាប់មាន ក្សត្រពីបុរាណ បរមរឿងរាជ បើពុំទ្រង់ធម៌ សម្មាឯងអាច អាងព្រះអំណាច ខុសច្បាប់ហើយណ៎ា ។ មុខមន្ត្រីធំ អ្នកប្រាជ្ញាជំនុំ គិតព្រមគ្នីគ្នា បណ្ដេញស្ដេចបង់ ពីក្នុងនគរា ត្បិតស្ដេចពុះពារ បំពាក់បំពាន ។ បើរាស្ដ្រមន្ត្រី ពុំដោយច្បាប់ពី បរមបុរាណ ល្មមលក់ល្មមព្នៃ ល្មមឱ្យក្ស័យបានចៅខំប៉ុន្មាន អញពុំបើកទ្បើយ ។

## បទព្រហ្មគីតិ

កាលនោះឯមហាក្សត្រ ព្រហ្មទត្តតើនទ្បើងហើយ ហទ័យសោតពុំស្បើយ គិតទៅដល់មាយើងថា ។ មាយើងមានគុណក្រៃ កាលនៅព្រៃមានតែមា យើងឥតនរណា ក្រៅអំពីមាយើងទ្បើយ ។ ឥឡូវនេះអញប្រើ ឱ្យគេធ្វើគុតគាត់ហើយ គេកាប់ឬនៅទ្បើយ អះអញស្ដាយពេកណាស់ណា ។ ស្ដេចត្រាស់ឱ្យអាមាត្យ រត់ខ្មីឃ្មាតរួសម្ទីម្នា ទៅតាមយក

ចៅមា យើងមកវិញកុំពិឃាដ ។ កាលនោះអមច្ចា ក្រួញក្រាបលារត់សង្វាត តាមទាន់ពេជ្ឈឃាដ នៅនាទ្វារខុត្តរនោះ ។ ទើបនាំមាយើងមក វិលវឹងមកថ្វាយក្សត្រស្មោះ ទើបស្ដេចបន្ទូលឆ្ពោះ ដណ្ដឹងចៅមាយើងថា ។ ហៃមាយើងអើយចៅ កាលអញទៅលេងព្រឹក្សា អញយល់មាឯងជា មានគំនិតគំនូរ ក្រៃ ។ ឥឡូវម្ដេចចៅគិត ប្រាណប្រែចិត្តទៅទីទៃ ចូរចៅចែងសម័យ ចរចាមកឥឡូវវ៉ា ។ មាយើងទូលពិនិត្យ ថាបពិត្រព្រះរាជា ក្នុងកាលយប់មិញណា ពស់វាមកខាំក្សត្រថ្លៃ ។ ខ្ញុំកាប់ពស់អន្តរាយ លោហិតខ្ចាយពី ក្រោមក្រៃ ពេញព្រះថនានៃ វរទេវីពិសេសសល់ ។ ខ្ញុំពុំហ៊ានប្រមាថដាស់ព្រះបាទឱ្យអំពល់ នឹងយកដៃជិតដល់ សោតពុំគួរទើបខ្ញុំខំ ។ យកអណ្ដាតលិទ្ធឈាម កូវកើយខ្មាមពិតពុំសមជ្រាបដល់ព្រះអង្គអ- ម្ចាស់ ឱ្យចងយកទៅកាប់ ។ ខ្ញុំនឹងទូលក្សត្រក្សាន្ត ទាស់ពុំហ៊ានក្រែងខុសគាប់ អំពល់បើនឹងស្លាប់ តាមវេរាអំពើកម្ម ។ តេជះហេតុអំពើ ត្រង់ពុំធ្វើវេរាកម្ម ទើបខានដោយសារឆ្នាំ ទ្វារជំទាស់ពុំឱ្យទៅ ។ បើពុំពិចារណា គឺអសារសោះសូន្យសៅ ក្សិណក្ស័យជីវិតនៅ នាធរណីនាយឥតការ ។ ស្ដេចស្ដាប់ដណ្ដឹងឆ្ពោះ ថាបើច្នោះខ្មោចពស់ពាល ចៅទុកឯណាកាល ឥឡូវចៅប្រាប់អញហោង ។ មាយើងទូលទៅថា ខ្ញុំទុកជាបន្ទាល់ផង ទាំង ៣ កំណត់ហោង ក្រោមមន្ទីរទិព្វភូបាល ។ ទើបស្ដេចឱ្យទៅយក ខ្មោចពស់មកមែនដូចសា- សព្វចៅមាយើងកាល នោះព្រះអង្គជឿជាក់ស្ដែង ។ ក្សត្រថ្ងៃខ្ពង់ខ្ពស់ យល់ខ្មោចពស់ទ្រង់ស្ញប់ស្ញែង ព្រឺព្រួចប្រឹងគ្រញែង ព្រះសិរសីបន្ទូលថា ។ ភ័ព្វជាមាយើងអើយ កុំអីឡើយលុះមរណា ឱមាយើងមហា គុណអនេកអនន្តក្រៃ ។ អ្នកផងសឹងស្ញប់ស្ញែង ព្រឺគ្រញែងទីទៃ យល់គុណមាយើងក្រៃ ក្រាស់ឥតនឹងថ្លាថ្លែង ។ ស្ដេចឱ្យស្រេចស្រាយចំណង មាយើងហោងប្រោសលះលែង ទោសទុក្ខបង់វែង ហើយបន្ទូលដោះសាថា ។ ចៅអើយ ហេតុអញខ្លៅ ធ្វើទោសចៅឥតករុណា កុំចៅយកទោសា អញទទូលថាខុសហើយ ទើបស្ដេចគិតគុណក្រៃ ឱ្យយសថ្លៃឥតស្មើឡើយ ដល់មាយើងជាត្រើយ ជាមន្ត្រីធំកន្លង ។ នរៈអ្នកសឹងចុះឡើង ចៅមាយើងឥតផ្ទឹមផង ហេតុបានភរិយាគ្រង កបលក្ខណាសួគ៌សល់ស្រី ។

## បទកាកគតិ

និទានមាយើង បានយកចុំថ្កើង សាន្តសំរឹទ្ធី ស្លេះទុកទើបថ្លែង សំដែងស្រដី ដំណាលអំពី អ្នកនាយភោត្រា ។ បានមេកញ្ជើ ផ្លុះអរលលើ ទៅជាភរិយា ដោយវាពុំមាន ធនធានទ្រព្យា លុះបានហើយវា ធ្វើឆ្មើងធំក្រៃ ។ ស្លៀកខៀនស្លៀកព្រៃ ស្អាងខ្លួនបន្ថែ ផ្ចិតផ្ចង់សព្វថ្ងៃ អាងប្ដីមានទ្រព្យ ប្រដាប់ច្រើនក្រៃ ថាខ្លួនវាថ្លៃ ឥតគេផ្ទឹមផង ។ វាពុំស្រដី ទ្រព្យធនអ្វី ៗ ពុំបានស្ងួនគ្រង ស៊ីចាក់ស៊ីចោល បាចសាចជាម្ដង មានកូនមួយផង នឹងនាយនោះនៃ ។ បើកូននោះជុះ មេកញ្ជើផ្លុះ ពុំលាងវិស័យ ដូចអ្នកទាំងគ្រប់ អាងទ្រព្យច្រើនក្រៃ ហែកព្រៃថ្លៃៗ ជូតអាចម៍ចោលទៅ ។ លង់លុះវែងឆ្ងាយ ក្សិណខ្សត់អន្តរាយ ទ្រព្យទាំងសំពៅ ប្រែជាអ្នកខ្សត់ ទុគ៌តអាសៅ លក់ទាំងសំពៅ ស៊ីចាយអស់ហោង ។ ហេតុស្រីខាតលក្ខណ៍ ពុំចេះទុកដាក់ រក្សាស្ងួនគ្រង ឱ្យអាប់យសប្ដី អប្រិយកន្លង សព្វថ្ងៃនេះហោង សុំទានគេស៊ី ។ កម្សោយកម្សត់ អប្រិយកន្លង ហិនហោចទុគ៌ត ដើរដោយប្រឹថពី ស្វែងរកសុំទាន សព្វឋានទិសទី ចិញ្ចឹមជីវី ជីវិតសព្វថ្ងៃ ។ សុំទានរៀងទៅ ដូចដល់លំនៅ ផ្ទះមាយើងវ៉ៃ នាងយល់អ្នកខ្សត់ ទុគ៌តក្រក្រៃ ស្មានអ្នកដទៃ ហើយឱ្យទានទៅ ។ លុះគន់ជាក់លាក់ នាងស្គាល់ជាអ្នក ចៅនាយសំពៅ ប្ដីដើមនៃនាង ទើបនាងថាទៅ ឱនាយសំពៅ ម្ដេចដើរសុំទាន ។ ប្ដូរផ្ដាច់បោះបង់ អញឥតមានស- ង្ស័យអញស្មោះស្មាន នឹងកើតរបស់ ស័ក្ដិយសធនធាន ឥឡូវម្ដេចប្រាណ ប្រែខ្លួនទទេ ។

ល្អពេកមុខចៅ ចៅនាយសំពៅ ដើរសុំទានគេ ស្រឡាញ់ប្រពន្ធ ល្អលន់មុខមេ កញ្ជើផ្លុះទេ ល្អពេកប្រាកដ ។ នេះហេតុលក្ខណ៍ស្រី គេចម្រើនប្ដី បរិបូណ៌បានបទ ស្រីយើងចង្រៃ ពេកក្រៃប្រាកដ នៅនឹងអ្នកខ្សត់ ប្រែជាអ្នកមាន ។

មនុស្សខ្សត់ទាំងពីរ ឮហើយរមិល មើលនាងកល្យាណ ស្គាល់ជាក់ហើយខ្មាស អាស្រូវភាសភាន ចៀសចេញទៅឋាន លំនៅអាត្មា ។ មាយើងមានយស ឧត្ដមខ្ពង់ខ្ពស់ ត្បិតភរិយាយសយឺនពណ្ណរាយ កេរ្តិ៍ឆ្ងាយសោះសា ប្រាកដប្រុះប្រា -កបកេរ្ដិ៍វែងឆ្ងាយ ។

រីឯសភាព ដំណើរកិរកាព្យ មានពីព្រេងនាយ បរមបុរាណ និទាននិយាយ អស់អាថ៌បរិយាយ ចែងចប់ម្ល៉េះហោង ៕